ទីស្តីការក្រសួងយុត្តិធម៌
លេខ ១៤៤៨.កយអក/០៦

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ
## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

លោក លោកស្រី ប្រធានតុលាការខេត្ត-ក្រុង
លោក ព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង

*សូមជ្រាប។*

**កម្មវត្ថុ:** អំពីការសរសេរលិខិតបញ្ជូនព័ត៌មាន ឬទំនាក់ទំនងការងារជាមួយស្ថានទូតនានា ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងជាមួយក្រសួងនានា ឬស្ថាប័នពាក់ព័ន្ធ របស់រាជរដ្ឋាភិបាល ក្នុងការចោទប្រកាន់ ចាប់ខ្លួន ឬឃាត់ខ្លួនជនសង្ស័យ ។

**យោង:** -លិខិតលេខ ៣៦៦០ កបទ-សអ/ច្បក២ ចុះថ្ងៃទី០២-០៦-២០០៦ របស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ។

-លិខិតលេខ ១៩៦ អក/២០០១ ចុះថ្ងៃទី១៥-០២-២០០១ របស់ក្រសួងយុត្តិធម៌ ។

ខ្ញុំសូមជម្រាបលោក លោកស្រី ជ្រាបថា ក្រសួងយុត្តិធម៌បានពិនិត្យឃើញថា កន្លងមកនេះតុលាការ អយ្យការខេត្ត-ក្រុង មួយចំនួនពុំទាន់អនុវត្តអោយបានត្រឹមត្រូវអំពីបែបបទរដ្ឋបាល ក្នុងការទំនាក់ទំនងការងារជាមួយស្ថានទូតបរទេស ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ក៏ដូចជា ជាមួយស្ថាប័ន និងក្រសួងពាក់ព័ន្ធនានា របស់រាជរដ្ឋាភិបាល ។

ដើម្បីអោយការអនុវត្តខាងលើ មានភាពរលូន និងសមស្របតាមឋានុក្រមនៃបែបបទរដ្ឋបាល ក្រសួងសូមធ្វើការណែនាំដូចខាងក្រោមនេះ ៖

១-ការទំនាក់ទំនងការងារ ឬការជូនព័ត៌មានផ្សេងៗទៅស្ថានទូតបរទេសនានា ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា តុលាការអយ្យការខេត្ត-ក្រុងទាំងអស់ត្រូវធ្វើតាមរយៈរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក្រសួងនឹងបញ្ជូនការទំនាក់ទំនងការងារ និងព័ត៌មានខាងលើ ទៅក្រសួងការបរទេស និងសហប្រតិបត្តិការ អន្តរជាតិ ដើម្បីចាត់ការជាសមត្ថកិច្ចបន្ត ។

២-គ្រប់ការជូនដំណឹងស្តីពីការចោទប្រកាន់ ការចាប់ខ្លួន ឬការឃាត់ខ្លួន មន្ត្រីរាជការ ទាំងយោធា និងស៊ីវិលទៅស្ថាប័ន ឬ ក្រសួងពាក់ព័ន្ធ តុលាការ អយ្យការខេត្ត-ក្រុងទាំងអស់ត្រូវធ្វើលិខិតជូនដំណឹងតាមរយៈរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក្រសួងនឹងបញ្ជូនការជូនដំណឹងខាងលើ ទៅស្ថាប័ន និងក្រសួងដែលពាក់ព័ន្ធទាំងអស់នោះ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមលោក លោកស្រី អនុវត្តអោយបានម៉ឺងម៉ាត់ តាមការណែនាំនេះឲ្យមានប្រសិទ្ធិភាព ។

សូមលោក លោកស្រីទទួលនូវការរាប់អានអំពីខ្ញុំ ។

ភ្នំពេញ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៦
**រដ្ឋមន្ត្រី**

**អង្គ វង្សវឌ្ឍានា**

ចម្លងជូន
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
-តុលាការកំពូល
-មហាអយ្យការអមតុលាការកំពូល
-សាលាឧទ្ធរណ៍
-មហាអយ្យការអមសាលាឧទ្ធរណ៍
-ដើម្បីជូនជ្រាប
-ឯកសារ -កាលប្បវត្តិ